សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងឱកាសអបអរសាទរ " ទិវាជាតិលើកកម្ពស់អនាម័យជនបទ លើកទី ០១ "

## ក្រោមប្រធានបទ "ការលើកកម្ពស់អនាម័យតាមជនបទ"

## ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

- សូមក្រាបថ្វាយបង្គំ សម្ដេចព្រះអគ្គមហាសង្ឃរាជ សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- បងប្អូនជនរួមជាតិជាទីស្នេហា

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាមួយប្រជាជនទូទាំងប្រទេស និងថ្លែងទៅកាន់ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ក្នុងឱកាសនៃការប្រារព្ធ "ទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា ឆ្នាំ ២០១០" ក្រោមប្រធានបទ "**ការលើកកម្ពស់អនាម័យតាមជនបទ**"។

ក្នុងគោលបំណងជំរុញ និងបំផុសការយកចិត្តទុកដាក់កាន់តែខ្ពស់ ក្នុងការលើកកម្ពស់អនាម័យជនបទ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី ១៣ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទនៅកម្ពុជា សំដៅកែលំអសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលមានវិសាលភាពដ៏ធំធេងក្នុងការថែរក្សាសុខភាព បង្កើនការសិក្សារៀនសូត្រ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ខ្ញុំព្រះករុណាខ្ញុំយល់ថា ប្រធានបទនេះពិតជាមានសារៈប្រយោជន៍ជាទីបំផុត ក្នុងការរួមចំណែកអភិវឌ្ឍសហគមន៍ជនបទនៅកម្ពុជា សម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០១៥ ដែលបានកំណត់ថា ប្រជាជនកម្ពុជារស់នៅជនបទ ៥០% នឹងបានទទួលសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និង ៣០% បានទទួលសេវាកម្មអនាម័យ និងការប្រតិបត្តិអនាម័យល្អក្នុងគ្រួសារ ។

ទិន្នន័យជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨ ដែលបានដឹកនាំ និងរៀបចំដោយក្រសួងផែនការ បានបង្ហាញថា គ្រួសារនៅជនបទដែលមានលទ្ធភាពទទួលបានសេវាទឹកស្អាតប្រើប្រាស់មាន ៤១% និងអនាម័យមាន ២៣.២% ។ តួលេខនេះបានបង្ហាញថា ការប្រតិបត្តិអនាម័យនៅតំបន់ជនបទមានកម្រិតមួយទាបនៅឡើយ ដែលទាមទារឲ្យមានការខិតខំបន្ថែមទៀត ដើម្បីលើកកម្ពស់អនាម័យ ក្នុងនោះប្រជាជនទាំងអស់ត្រូវយល់ដឹងអំពីការប្រតិបត្តិអនាម័យល្អ ០៣ យ៉ាង គឺ÷ ១-ការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ ២-ការលាងសម្អាតដៃជាមួយសាប៊ូក្រោយពេលបន្ទោបង់ និងមុនបរិភោគអាហារ ៣-បរិភោគទឹកស្អាត និងរក្សាទុកទឹកបរិភោគឲ្យមានសុវត្ថិភាពនៅក្នុងផ្ទះ ។ ការយល់ដឹងសារគន្លឹះទាំងបីនេះមានសារៈសំខាន់ខ្លាំងណាស់ ដល់ការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថ ក្នុងការប្រតិបត្តិអនាម័យល្អដើម្បីសុខភាពខ្លួនយើង និងកូនចៅរបស់យើងក្នុងក្រុមគ្រួសារ ។

ជាការពិត ការលើកកម្ពស់អនាម័យ ជាបញ្ហាប្រឈមដ៏ធំមួយនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ពីព្រោះត្រូវការជំរុញឲ្យប្រជាជនផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថ ។ ដើម្បីប្រសិទ្ធភាពនៃការលើកកម្ពស់អនាម័យជនបទ រាជរដ្ឋាភិបាលបានអភិវឌ្ឍគោលនយោបាយសាធារណៈ ជំរុញឲ្យវិស័យឯកជនបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ រីឯគ្រួសារនីមួយៗត្រូវផ្តល់អាទិភាពខ្ពស់លើការសាងសង់បង្គន់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ការទុកដាក់កាកសំណល់ឲ្យមានសុវត្ថិភាព និងទម្លាប់ប្រតិបត្តិអនាម័យល្អ គឺជាមូលដ្ឋានគ្រឹះសម្រាប់ភាពថ្លៃថ្នូរ និងសុភមង្គល។

ដើម្បីអនុវត្តកិច្ចការទាំងអស់នេះបាន រាជរដ្ឋាភិបាលសំណូមពរឲ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសពីប្រជាជន ក្នុងការជំរុញ **ការលើកកម្ពស់អនាម័យនៅជនបទ** និងការផ្លាស់ប្តូរផ្នត់គំនិត និងទម្លាប់របស់ប្រជាជន ក្នុងការប្រតិបត្តិអនាម័យល្អ ។

**- បងប្អូនជនរួមជាតិជាទីស្នេហា**

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា សុខភាពប្រជាជន គឺជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។ នេះគឺជាគោលដៅចម្បងរបស់រាជរដ្ឋាភិបាល ដែលធ្វើឲ្យប្រជាជនមានជីវភាពសម្បូររុងរឿង និងមានសុខមាលភាពល្អប្រសើរ។

ជាថ្មីម្តងទៀតក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបងប្អូនជនរួមជាតិទាំងអស់ សូមចូលរួម និងគាំទ្រទិសដៅទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា ដើម្បីបំផុសឲ្យប្រជាជនយើងអនុវត្តការប្រតិបត្តិអនាម័យល្អ ០៣ យ៉ាង ដើម្បីសម្រេចឲ្យបាននូវគោលដៅលើក

កម្ពស់អនាម័យជនបទ ស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០១៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលរាជរដ្ឋាភិបាលបានកំណត់។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរដល់បងប្អូនជនរួមជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ និងសូមអរគុណ !**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

**ហ៊ុន សែន**